មជ្ឈមណ្ឌលឯកសារកម្ពុជា

# របាយការណ៍ស្តីពីការស្រាវជ្រាវនៅខេត្តក្រចេះ
# កាលពីថ្ងៃទី២៤ដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០២

ដោយៈ ផេង ពង្សរ៉ាស៊ី និង ស៊ិន ឃិន

នាព្រឹកព្រលឹមម៉ោង៦កន្លះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជារួមមាន ស៊ិន ឃិន, ផេង ពង្សរ៉ាស៊ី, អ៊ុច សំអឿន និងអ្នកបើកបររថយន្តម្នាក់បានធ្វើដំណើរទៅកាន់ខេត្តក្រចេះតាមបណ្តោយផ្លូវជាតិលេខ៦អា ឆ្លងកាត់ខេត្តកំពង់ចាមតាមស្ពានទន្លេបិទឆ្ពោះត្រង់ទៅរកស្រុកស្នួល ខេត្តក្រចេះ ។ រួចទើបធ្វើដំណើរបន្តទៅកាន់ទីរួមខេត្តក្រចេះដែលមានចម្ងាយជាង៨០គីឡូម៉ែត្រពីទីរួមស្រុកស្នួល ។ គោលបំណងដំបូងរបស់ខ្ញុំគឺធ្វើដំណើរទៅកាន់ស្រុកសំបូរមុនគេ បន្ទាប់មកគឺស្រុកស្នួល និងចុងក្រោយគឺស្រុកឆ្លូង ។

## ស្រុកសំបូរ

ស្រុកសំបូរជាស្រុកមួយដែលស្ថិតនៅប៉ែកខាងជើងឈៀងខាងលិចទីរួមខេត្តក្រចេះ ។ ខ្ញុំបានធ្វើដំណើរចេញពីទីរួមខេត្តក្រចេះតាមបណ្តោយផ្លូវលេខ១៣ (ទិសដៅពីខេត្តក្រចេះទៅខេត្តស្ទឹងត្រែង) ប្រហែលជាង៦០គីឡូម៉ែត្រទើបទៅដល់សាលាស្រុកសំបូរដែលមានទីតាំងស្ថិតនៅខាងកើតទន្លេមេគង្គ ។ ដោយស្ថានភាពអាកាសធាតុមិនអំណោយផល ខ្ញុំនិងក្រុមស្រាវជ្រាវបានសម្រេចចិត្តធ្វើការទៅលើទីតាំងតែមួយកន្លែងគត់នៅស្រុកសំបូរនេះ ។ ទីតាំង

នោះគឺៈ

ទីតាំងកោះសំតូច (មន្ទីរឃុំឃាំង និងកន្លែងសម្លាប់)

លេខកូតភូមិសាស្ត្រ ១០០៤០៣

រយៈកំពស់ **(N) 12º 44'31:71"**

រយៈទទឹង **(E) 105º 59'14:17"**

កោះសំជាឈ្មោះកោះពីរនៅចំកណ្តាលទន្លេមេគង្គដែលស្ថិតនៅក្នុងទឹកដីស្រុកសំបូរ ខេត្តក្រចេះ ។ អ្នកភូមិបាននាំគ្នាហៅកោះដែលតូចថាជា "កោះសំតូច" ។ ឯឈ្មោះ"កោះសំធំ" បានត្រូវផ្តល់ទៅឲ្យកោះដែលធំជាងគេ ។ កោះទាំងពីរនេះស្ថិតនៅចម្ងាយពីគ្នាប្រហែលមួយគីឡូម៉ែត្រ ។ តាំងពីយូរយារណាស់មកហើយកោះទាំងពីរនេះមិនដែលមានមនុស្សរស់នៅទេទោះជាក្នុងស្ថានភាពបែបណាក៏ដោយ ។ ប៉ុន្តែបែរជាមានក្រុមគ្រួសារខ្លះបាននាំគ្នាទៅធ្វើស្រែចម្ការនៅលើកោះទាំងពីរនេះ ។ ដំណាក់កាលក្រោយមកកោះនោះត្រូវបានកាន់កាប់ធ្វើជាកម្មសិទ្ធរបស់ខ្លួនរហូតទាល់តែមានការផ្លាស់ប្តូររបបពីមួយជំនាន់ទៅមួយជំនាន់ ។ ក្រុមគ្រួសាររបស់ឈ្មោះវៃ ប្រណី គឺជាម្ចាស់កម្មសិទ្ធនៃកោះនោះតាំងពីរបបសម្តេចសីហនុមកម្ល៉េះ ។ ឪពុករបស់គាត់តែងតែទៅធ្វើ

ស្រែចម្ការនៅលើ«កោះសំតូច»ជារៀងរាល់រដូវ ។ ការប្រកបការងារធ្វើស្រែចម្ការរបស់គាត់បានត្រឹមតែឆ្នាំ ១៩៧០ប៉ុណ្ណោះក៏ត្រូវរឹបអូសយកធ្វើជាកម្មសិទ្ធរបស់រដ្ឋការសម័យខ្មែររំដោះ ។ មន្ទីរអប់រំកែប្រែប្រចាំស្រុកសំបូរមួយកន្លែងបានត្រូវផ្តួចផ្តើមឲ្យបង្កើតនៅលើកោះសំតូចនេះបន្ទាប់ពីមានការដកហូតរួចមក ។ ចំណែកឯម្ចាស់កោះក៏បានត្រូវចាប់ខ្លួនហើយក្រោយមកបានស្លាប់ដោយការចងជាប់ជាមួយនឹងថ្មទម្លាក់ក្នុងទន្លេ ។ រឿងរ៉ាវទាំងឡាយដែលនាំឲ្យកើតមានការឃុំឃាំងនិងសម្លាប់នេះ គឺដោយសារតែមានការប្រទាញប្រទង់គ្នារវាងអ្នកនៅខាងខ្មែររំដោះនិងអ្នកនៅខាងរបបសាធារណរដ្ឋខ្មែរ ។ មានមនុស្សនៅក្នុងស្រុកសំបូរជាច្រើនបានត្រូវបញ្ជូនមកកាន់កោះនេះព្រោះមូលហេតុមានការពាក់ពន្ធ័នឹងការជាប់ខ្សែជាមួយខ្មាំង ។ ចំណែកអ្នកផ្សេងទៀតដែលបានជម្លៀសមកពីកន្លែងឆ្ងាយៗដូចជាពីខេត្តកំពង់ចាមជាដើម ក៏បានមកជាប់ឃុំឃាំងនៅលើកោះសំតូចដែរ ។ តែ គី ប៊ិន បានត្អូញត្អែរពីសាច់ញាតិរបស់គាត់ដែលបានស្លាប់ដោយសារការជាប់ពាក់ពន្ធ័ទៅនឹងនិន្នាការពីសង្គមចាស់ ។ វ៉ៃ ប្រណី និងអ្នកឯទៀតក៏ដូច្នេះដែរ សុទ្ធតែនិយាយដោយផ្ទាល់មាត់ថាមានបង, ប្អូន, ឪពុកបានត្រូវសម្លាប់នៅលើកោះសំតូច ព្រោះរឿងមានបុណ្យសក្តិបន្តិចបន្តួចជាមួយរដ្ឋការនៃរបបលន់ ណុល ។ ពុត រៀម គឺជាចាស់ទុំម្នាក់នៅក្នុងភូមិកែងប្រាសាទ ឃុំសំបូរនាពេលបច្ចុប្បន្ននេះ ក៏បាននិយាយប្រាប់ពីការចាប់ខ្លួនគាត់យកទៅដាក់ទណ្ឌកម្មនៅលើកោះសំតូចដោយគ្មានមូលហេតុកាលពីឆ្នាំ១៩៧៤ដែរ ។ រហូតមកដល់សព្វថ្ងៃ រៀម នៅតែពុំបានដឹងពិតប្រាកដពីមូលហេតុនៃការចាប់ខ្លួនរបស់គាត់ឡើយ ប៉ុន្តែ រៀម មានមន្ទិលសង្ស័យក្នុងចិត្តថាប្រហែលមកពី គាត់ធ្លាប់ធ្វើជាតម្រួតយោធា(ប៉េអឹម)សម័យសង្គមរាស្ត្រនិយមហើយមើលទៅ ។ ទោះជាយ៉ាងនេះក៏ដោយ រៀម មិនព្យាយាមសួររកមូលហេតុនេះទេព្រោះគាត់គិតថារឿងរ៉ាវបានកន្លងហួសទៅហើយ ។ រៀម បាន ជាប់ឃុំនៅលើកោះសំតូចតែរយៈពេល៤ខែប៉ុណ្ណោះ ។ ការងាររលត់ដីជាច្រើនបានត្រូវប្រគល់ឲ្យគាត់ធ្វើដោយកម្មាភិបាលខ្មែរក្រហមដែលប្រចាំការនៅលើកោះនេះ ដូចជាកាប់ឆ្ការព្រៃ, ភ្ជួរដី ធ្វើចម្ការ, ដាំពោត, សណ្តែក ។ល។ ក្រៅពីនេះទៅនៅមានការងារហត្ថកម្មផ្សេងៗទៀត ។ ពេលយប់ រៀម និងអ្នកទោសដទៃទៀតបានសម្រាកនៅលើធ្នើយ៉ាងវែងមួយដែលមានកំពស់ប្រមាណ២០សង់ទីម៉ែត្រពីដីនៃរោងប្រក់ស្បូវគ្មានជញ្ជាំងមួយនៅចំកណ្តាលកោះ ។ គ្មានសម្លៀកបំពាក់ និងមុងខ្នើយសម្រាប់អ្នកទោសធុនពួកគាត់នេះឡើយ ។ ពុត រៀម បាននិយាយទៀតថារោងដែលពួកគាត់ស្នាក់នៅរាល់យប់ គឺជាអតីតមន្ទីរអប់រំកែប្រែកាលពីឆ្នាំ១៩៧២-៧៣ ។ ប្រជាជនដែលបានចូលមកដល់ទីតាំងនេះពុំសូវមានជីវិតរស់ទៅវិញទេ ព្រោះជាអ្នកដែលមានប្រវត្តិរូបមិនស្អាតស្អំ ។ តែ គីប៊ិន អាយុ៥១ឆ្នាំជាមន្ត្រីសាលាស្រុកសំបូរបានអធិប្បាយប្រាប់ថា ប្រជាជនដែលជាប់ឃុំឃាំងនៅលើកោះសំតូច គឺជាប្រជាជនដែលបានជម្លៀសមានពីឃុំតាមូង ស្រុកដំបែរ ខេត្តកំពង់ចាម ។ ការជម្លៀសនេះគឺធ្វើឡើងនៅឆ្នាំ១៩៧២-៧៣ ។ ចំណែកឯនៅដើមឆ្នាំ១៩៧៥វិញ ក៏មានបញ្ជូនតាមទូកជាច្រើននូវចំនួនប្រជាជនដែលជម្លៀសមកពីទីក្រុងភ្នំពេញទៅកាន់មន្ទីរ ឃុំឃាំងកោះសំតូច

ហើយក្រោយមកអ្នកទាំងនោះបានត្រូវសម្លាប់ទាំងអស់ ។ អ៊ុង សាម៉ុន គឺជាអ្នកគ្រប់គ្រងមន្ទីរឃុំឃាំងនេះតាំងពីឆ្នាំ១៩៧០ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៥ អ៊ុង សាម៉ុន បានត្រូវចាប់ខ្លួនពីមូលហេតុចោទថាបានក្បត់ទៅចូលដៃដើងជាមួយបក្សពួកឈ្មោះ ឈុន យោម និងថែត ដែលជាសមាជិកក្រុមសេអ៊ីអាខាងខ្មែរស ។ ឈុន យោម និង ថែត គឺជាចៅហ្វាយនិងអនុចៅហ្វាយស្រុកសំបូរកាលពីអំឡុងឆ្នាំ១៩៧០-៧៥ ។ សាម៉ុន និងបក្សពួកបាន ត្រូវបញ្ជូនទៅកាន់ឃុំក្រោន (ឃុំជនជាតិ) ស្រុកសំបូរដើម្បីឃុំខ្លួនបណ្តោះអាសន្នមុនពេលសួរចម្លើយ និងសម្លាប់ចោល ។

បន្ទាប់ពីចាប់ខ្លួនអ៊ុង សាម៉ុន មន្ទីរឃុំឃាំងលើកោះសំគួចបានត្រូវរំលាយចោលដោយជំនួសការកាន់កាប់នេះទៅឲ្យខាងមន្ទីរពេទ្យស្រុកជាអ្នកមើលការខុសត្រូវវិញ ។ ការងារកសិកម្មជាច្រើនបានត្រូវអនុវត្តឡើងនៅលើកោះនេះ ។ ផលិតផលដែលសម្រេចបានពីការងារនេះបានត្រូវប្រគល់ និងចែកចាយទៅឲ្យខាងស្រុកដើម្បីជាការបម្រើដល់គ្រប់សហករណ៍នានាទូទាំងស្រុកសំបូរ ។ ការងារនេះនៅតែបន្តធ្វើឡើងរហូតទាល់តែដល់ថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ចូលមកដល់ ។ នៅក្រោយឆ្នាំ១៩៧៩ កោះសំគួចបានត្រូវប្រគល់ទៅឲ្យម្ចាស់ដើមវិញ ហើយដែលបច្ចុប្បន្នកោះនេះត្រូវទុកចោលហាក់ដូចជាគ្មានការថែទាំ ឬប្រកបរបរអ្វីឡើយ ។ វៃ ប្រណីគឺជាម្ចាស់កោះសំគួចនាពេលបច្ចុប្បន្ននេះ ។ ប្រណី បានរៀបរាប់ពីមូលហេតុនៃការមិនទៅធ្វើចម្ការស្រែនៅលើកោះថានាំឲ្យគាត់នឹកឃើញរឿងដែលឪពុករបស់គាត់បានត្រូវសម្លាប់ ដោយសារតែខ្មែរក្រហមចោទប្រកាន់ថាជាអ្នកមូលធន សក្តិភូមិ....។ ប្រណី បន្តទៀតថា កោះនេះហាក់ដូចជាស្ងាត់ និងមានសត្វសាហាវច្រើនផង ។

តែ គី ប៊ិនបានឡើងទៅលើកោះសំគួចនៅក្រោយពេលបែកឆ្នាំ១៩៧៩ថ្មី ដើម្បីទៅរកបងប្រុសរបស់គាត់ឈ្មោះ ឃី ស៊ុយ ឡាយ ដែលបានចាប់ខ្លួនមកកាលពីអំឡុងឆ្នាំ១៩៧២-៧៣ ព្រោះតែ ស៊ុយ ឡាយ ជានាយកសាលាបឋមសិក្សា ។ ដំណើរស្វែងរករបស់ គី ប៊ិន ត្រូវខកបំណង ព្រោះបងរបស់គាត់បានត្រូវសម្លាប់ទៅហើយនៅក្នុងរយៈពេលបន្ទាប់ពីការចាប់ខ្លួនតាំងពីឆ្នាំ១៩៧២-៧៣ ។ គី ប៊ិន បានសង្កេតឃើញមានខ្នោះឈើ និងចំរូងជាច្រើននៅរាយប៉ាយពេញទីធ្លានៃមន្ទីរឃុំឃាំង និងកន្លែងឯទៀតនៅលើកោះ ។ មានស្នាមឈាមថ្មីៗនៅពាសពេញស្មៅ និងដី ។ ហេតុការណ៍នេះបានធ្វើឲ្យ គី ប៊ុន ភ័យតក់ស្លុតយ៉ាំខ្លាំងព្រោះគាត់មិនដែលឃើញកើតមានពីមុនមក ។ សំណល់ភស្តុតាងទាំងអស់នេះ បានធ្វើឲ្យ គី ប៊ុន នឹកគិតដល់ក្លាមពីការសម្លាប់មនុស្សយ៉ាំងសាហាវនារបបកម្ពុជាប្រជាធិបតេយ្យ ។

ខ្ញុំ និងក្រុមស្រាវជ្រាវក៏បានឡើងទៅលើកោះសំគួចជាមួយ តែ គី ប៊ិន ដើម្បីពិនិត្យមើលទីតាំង និងក្នុងបំណងប្រើប្រាស់ម៉ាស៊ីនកំណត់ទីតាំងភូមិសាស្រ្តពិភពលោកផង ។ ហ្វូងសត្វមូស និងសត្វល្អិតផ្សេងទៀតបានទទួលស្វាគមន៍ខ្ញុំនិងអ្នកឯទៀតយ៉ាំងខ្លាំងស្ទើរឈរពុំបាន ។ ភ្លៀងមួយមេបានធ្លាក់មកចំពេលដែលខ្ញុំកំពុងឈរសម្ភាសន៍សាក្សីនៅលើកោះសំគួច ។ ខ្ញុំមានអារម្មណ៍ព្រឺក្បាលខ្វាកៗពីសភាពស្ងប់ស្ងាត់នៃកោះនោះ បូក

រួមជាមួយនឹងការខ្លាចកើតមាននូវជម្ងឺគ្រុនចាញ់តាមរយៈមូសខាំផង ។ ក្រុមខ្ញុំបានប្រញាប់ប្រញាល់ត្រឡប់មកវិញទាំងភ្លៀងកំពុងធ្លាក់យ៉ាងខ្លាំង ។ រយៈចម្ងាយ៨គីឡូម៉ែត្រពីប្រាំង ខ្ញុំមើលអ្វីមិនឃើញឡើយ ។ អ្នកបញ្ជាទូកបានខិតខំព្យាយាមបញ្ជាទូកឲ្យចូលចំទិសដៅរបស់ខ្លួនទាំងអារម្មណ៍តក់ស្លុត ។

## ទីតាំងសម្លាប់ចុងកោះសំតូច

អ្នកទោសដែលបានបញ្ជូនមកកាន់មន្ទីរឃុំឃាំងលើកោះស្ទើរតែទាំងអស់បានត្រូវនាំយកទៅសម្លាប់នៅប៉ែកខាងចុងកោះ ដែលស្ថិតនៅភាគខាងជើងមន្ទីរឃុំឃាំងប្រហែល៤០០ម៉ែត្រ ។ តែ គី ប៊ិន បានរៀបរាប់ពីការសម្លាប់មនុស្សនៅចុងកោះប្រាប់ទាំងខ្លួនទទឹកជោកថា ការសម្លាប់បានប្រព្រឹត្តទៅតាំងពីមន្ទីរអប់រំកែប្រែកកើតដំបូងនៅឆ្នាំ១៩៧០ម្ល៉េះ ។ ភាគច្រើននៃការសម្លាប់គឺវ៉ៃទម្លាក់ទឹកទន្លេ និងស្រដូនជាប់នឹងថ្មទម្លាក់ទៅបាតទន្លេ ។ ចំណែកឯការជីករណ្តៅកប់គឺមិនសូវកើតមានប៉ុន្មានទេ ។ ការសម្លាប់នេះបានធ្វើឡើងបន្ទាប់ពីមានការសួរចម្លើយរួច ។ គី ប៊ិន បន្តថាអ្នកទោសណាដែលមិនទាន់បានផ្តល់ចម្លើយត្រឹមត្រូវទេ គឺទុកមួយរយៈសិនឯអ្នកទោសណាដែលបានឆ្លើយអស់ហើយគឺត្រូវបញ្ជូនទៅសម្លាប់តែម្តង ។ មានអ្នកទោសរាប់រយនាក់បានត្រូវសម្លាប់ ។ មានតែរណ្តៅជាង១០ប៉ុណ្ណោះដែល គី ប៊ិន បានពិនិត្យឃើញ ។ រណ្តៅទាំងនោះជាប្រភេទរណ្តៅតូចល្មមដែលដាក់មនុស្សបានពីរឬបីនាក់ ។ រហូតមកដល់ពេលនេះរណ្តៅទាំងនោះមិនត្រូវបានគាស់ឡើយ ។

# ស្រុកស្នួល

១)ភ្នំកំណប់ (មន្ទីរសន្តិសុខ និងកន្លែងសម្លាប់)

លេខកូតភូមិសាស្រ្ត ១០០៥០២

រយៈកំពស់ **(N) 12º 14'32:76"**

រយៈទទឹង **(E) 106º 25'26:46"**

ភ្នំកំណប់ជាភ្នំមួយដែលស្ថិតនៅចម្ងាយប្រហែលជាមួយគីឡូម៉ែត្រពីផ្លូវលេខ៧(ស្នួល-ក្រចេះ) ប៉ែកខាងលិច ។ ខ្ញុំបានធ្វើដំណើរទៅកាន់ទីតាំងដែលជាអតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហមតាមផ្លូវឡើងលើភ្នំ និងបត់ចុះឡើងយ៉ាងវែងអន្លាយជាមួយនឹងអ្នកផ្តល់ព័ត៌មានម្នាក់ឈ្មោះ ព្រុំ អ៊ិន ដែលស្ថិតក្នុងសម្លៀកបំពាក់ជាអ្នកចម្ការ ។ គ្មាននៅសេសសល់ស្លាកស្នាមអ្វីបន្តិចសោះសម្រាប់ទុកជាវត្ថុតាងថាជាទីតាំងឃុំឃាំងមនុស្ស ។ នៅ នឹងទីតាំង ខ្ញុំនិងមិត្តរួមការងារបានប្រើប្រាស់ម៉ាស៊ីនកំណត់ទីតាំងភូមិសាស្រ្តពិភពលោកតាមផ្កាយរណបដើម្បី កំណត់យកចំណុចរយៈទទឹង និងរយៈកំពស់នៃទីតាំងប្រល័យពូជសាសន៍មួយនេះ ។ ព្រុំ អ៊ិនបាននិយាយប្រាប់ ខ្ញុំពេលកំពុងធ្វើដំណើរត្រឡប់មកវិញថា

ភ្នំកំណាប់នេះមិនត្រឹមតែជាមន្ទីរឃុំឃាំងប៉ុណ្ណោះទេ ថែមទាំងជាជម្រកស្នាក់អាស្រ័យរបស់កម្មាភិបាលខ្មែរក្រហមទៀតផង ។

មន្ទីរឃុំឃាំងលើភ្នំកំណាប់បានសាងសង់ឡើងនៅឆ្នាំ១៩៧២ដោយមានឈ្មោះ ផែន ជាប្រធានមន្ទីរនេះ ។ មានរោងជាង១០បានត្រូវធ្វើឡើងបន្តបន្ទាប់គ្នា ហើយរោងទាំងនេះបានធ្វើឡើងអំពីឈើប្រក់ស្បូវដែល មានទំហំទទឹង៧ម៉ែត្រ និងបណ្តោយ១០ម៉ែត្រ ។ មន្ទីរឃុំឃាំងនេះគ្រាន់តែជាមន្ទីរឃុំឃាំងរយៈពេលខ្លីប៉ុណ្ណោះ មុននឹងបញ្ជូនបន្តទៅសម្លាប់ចោល ឬទៅកាន់មូលដ្ឋានលត់ដំក្តៅនៅកន្លែងផ្សេង ។ ភិន គ្រឿន អាយុ៥៧ឆ្នាំ សព្វថ្ងៃជាប្រធានភូមិសំរ៉ែង ឃុំឃ្សឹម ស្រុកស្នួល បាននិយាយប្រាប់ថា អ្នកទោសដែលបានមកជាប់ឃុំឃាំងនៅក្នុងមន្ទីរឃុំឃាំងភ្នំកំណាប់នេះគឺជាប្រភេទអ្នកទោសធ្ងន់ដែលត្រូវសម្លាប់ហើយ ។ មានអ្នកទោសច្រើនណាស់បានមកជាប់ឃុំឃាំងនៅលើភ្នំកំណាប់ ក្នុងនោះរាប់បញ្ចូលទាំងទាហានខ្មែរក្រហមដែរ ។ ព្រុំ អ៊ិន បានរៀបរាប់រឿងរ៉ាវស្តីពីការចាប់មិត្តភក្រ័គាត់ចំនួនជាង៧០នាក់មកដាក់នៅក្នុងមន្ទីឃុំឃាំងភ្នំកំណាប់ដោយសារមូលហេតុថាបានក្បត់នឹងអង្គការបដិវត្ត, មានប្រវត្តិរូបមិនល្អ, មានបងប្អូនធ្លាប់ធ្វើជាទាហាន ឬមន្ត្រីរាជការជំនាន់លន់ណុល ។ល ។ មិត្តភក្រ័របស់ ព្រុំ អ៊ិនទាំងនោះគឺជាទាហានខ្មែរក្រហមឈរជើងនៅសមរភូមិមុខដែលមានតួនាទីការពារព្រំប្រទល់ដែន និងត្រៀមវាយយួន ។ អ៊ិន ក៏ធ្លាប់ត្រូវបានចាប់ខ្លួនម្តងដែរពីបទថាបានលួចបាយឲ្យខ្មាំងយួន ។ ក្រោយមក អ៊ិន បានរួចខ្លួន ហើយបានទទួលនាទីថ្មីជាប្រធានកងស្រួចបង្កបង្កើនផល ។ អាជីពការងារជាទាហានរបស់ អ៊ិន បានត្រូវបញ្ចប់នៅចុងឆ្នាំ១៩៧៤ ។ ចំណែកអ្នកដែលបានត្រូវចាប់ខ្លួនទាំងជាង៧០នាក់នោះ បានត្រូវបញ្ជូនបន្តទៅកាន់តំបន់កោះស្រការ និងអូរសំពោចតែក្នុងរយៈពេលជាងមួយសប្តាហ៍គិតចាប់តាំងពីថ្ងៃចាប់ខ្លួនដំបូងមកកាន់ភ្នំកំណាប់ ។ តំបន់កោះស្រការ និងអូរសំពោច គឺជាទីតាំងសម្លាប់ដ៏របស់ខ្មែរក្រហមប្រចាំស្រុកក្រចេះ ខេត្តក្រចេះ ។ អ៊ិន ធ្លាប់បានឃើញការធ្វើទារុណកម្មមកលើអ្នកទោសនៅលើភ្នំកំណាប់ និងបានមើលឃើញរោងឃុំឃាំងទាំងជាង១០ដែលបានសង់ថាមានគម្លាតពីគ្នាឆ្ងាយគ្រាន់បើដែរ ។ ការឃុំឃាំងមនុស្សនៅលើភ្នំកំណាប់ គឺមិនឲ្យលើសពីរយៈពេលមួយសប្តាហ៍ឡើយ ចាំបាច់ត្រូវបញ្ជូនបន្តទៅកាន់ទីតាំងសម្លាប់ដែលមានចម្ងាយឆ្ងាយពីមន្ទីរនេះ ។ មានអ្នកទោសថ្មីៗជាច្រើនទៀត បានត្រូវបញ្ជូនមកកាន់មន្ទីរឃុំឃាំងភ្នំកំណាប់ និងអនុវត្តរបៀបដដែលៗទៅលើអ្នកទោសក្រោយៗ ។

## ទីតាំងសម្លាប់ភ្នំកំណាប់

ក្រៅពីអ្នកទោសដែលត្រូវបញ្ជូនទៅកន្លែងផ្សេង នៅមានអ្នកទោសមួយភាគបានត្រូវសម្លាប់ចោលនៅនឹងកន្លែងឃុំឃាំងតែម្តង ។ សុខ ព្រុំ បានរាប់ចំនួនរណ្តៅនៅលើភ្នំកំណាប់ក្រោយថ្ងៃរំដោះក្លាមថាមានចំនួនជាង៣០រណ្តៅ ។ ការសម្លាប់បានប្រព្រឹត្តិទៅតាមការឆ្លើយបំភ្លឺនៅពេលសួរចម្លើយរបស់អ្នកទោស ប្រសិនបើឆ្លើយមិនត្រង់ គឺត្រូវសម្លាប់ចោលនៅនឹងកន្លែង ដើម្បីជាមេរៀនដល់អ្នកក្រោយៗ ។ សុខ ព្រុំ មិនអាច

សន្និដ្ឋានពីចំនួនមនុស្សស្លាប់នៅលើភ្នំកំណាប់បានឡើយ ព្រោះមិនបានឃើញដោយផ្ទាល់ភ្នែក ឬតាមរបាយការណ៍ដែលបានបន្សល់ឡើយ ប៉ុន្តែគាត់ធ្លាប់បានឃើញការបណ្តើរមនុស្សចូលទៅកាន់ក្នុងមន្ទីរទាំងខ្សែៗ ហើយមានអ្នកទោសខ្លះត្រូវបាន ព្រុំ ស្គាល់ច្បាស់ថាជាប្រជាជនដែលរស់នៅស្រុកមេមត់ ខេត្តកំពង់ចាម ។ គិតត្រឹម ឆ្នាំនោះ(២០០២) សុខ ព្រុំ មានអាយុ៦៧ឆ្នាំហើយ ប៉ុន្តែការចងចាំរបស់គាត់ពិតជាមិនអាចបំភ្លេចបានពី ជម្រៅចិត្តរបស់គាត់ឡើយ ។ ព្រុំ បានបន្តថា រហូតមកដល់សព្វថ្ងៃនេះ រណ្តៅទាំងជាង៣០ មិនទាន់មាននរណា គាស់ឡើយ ហើយក៏ប្រហែលមិនអាចរកឃើញស្លាកស្នាមទៀតដែរ ។

២) ព្រៃកូនង៉ែ (មន្ទីរសន្តិសុខ)

លេខកូតភូមិសាស្រ្ត ១០០៥០៣

រយៈកំពស់ **(N) 12º 06'34:50"**

រយៈទទឹង **(E) 106º 25'32:17"**

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលប្រជាជនភាគច្រើននៅទូទាំងប្រទេសត្រូវចាកចោលផ្ទះសម្បែងរបស់ខ្លួនតាមការស្នើសុំរបស់ពួកអាវខ្មៅដែលមានប្រដាប់ដោយកាំភ្លើងគ្រប់ដៃ ។ ការនិរាសត្តព្រាត់ប្រាស់គ្រួសារប្រពន្ធកូនបានចាប់ផ្តើមមានឡើងចំពោះប្រជាជនជម្លៀសទាំងនោះ ។ ទីជម្រកតាមជនបទដាច់ស្រយ៉ាលមួយចំនួន បានត្រូវជ្រើសរើសឲ្យស្នាក់នៅបណ្តោះអាសន្ននៃជនជម្លៀសពីភ្នំពេញ និងពីទីប្រជុំជនដទៃទៀត ។ នៅឯស្រុកស្នួល ខេត្តក្រចេះឯណោះវិញ ខ្មែរក្រហមបានជ្រើសរើសយក«ព្រៃកូនង៉ែ» ជាកន្លែងដាក់ប្រជាជនជម្លៀសមកពីទីកន្លែងឆ្ងាយៗ ។ ក្រោយមកព្រៃកូនង៉ែនេះ បានត្រូវបង្កើតជាកន្លែងឃុំឃាំងជនរងគ្រោះដែលភាគច្រើនបំផុតជាប្រជាជន១៧មេសា ។ ខ្មែរក្រហមបានចាប់ផ្តើមឲ្យមានការបំពេញប្រវត្តិរូបចំពោះអ្នកជម្លៀសទាំងអស់ ដោយបញ្ជាក់ថានឹងរៀបចំការងារដែលសម្រាប់សង្គមមួយថ្មីដល់នរណាម្នាក់ដែលធ្លាប់មានតួនាទីពីមុនមក ។ មានប្រវត្តិរូបជាច្រើនបានត្រូវបំពេញនិងបញ្ជូនទៅកាន់មន្ទីររបស់ខ្មែរក្រហម ។ គោលបំណងនៃការធ្វើប្រវត្តិរូបនេះ គឺខ្មែរក្រហមគ្រាន់តែចង់បានបញ្ជីដើម្បីបញ្ជូនទៅកាន់ថ្នាក់លើថាបានកម្ទេចអ្នកជាប់និន្នាការពីសង្គមចាស់ និងនិស្សិតបញ្ញវន្តដែលមាននៅក្នុងប្រវត្តិរូបនេះ ។ ក្រោយពីបានបំពេញប្រវត្តិរូបរួចរាល់មកការបំបែកហ្វូងមនុស្សបានចាប់ផ្តើមឡើង ដោយអ្នកដែលជាប់និន្នាការជាមន្ត្រី សិស្ស-និស្សិត ឬនគរបាលពីសង្គមចាស់ត្រូវបន្តទុកនៅឃុំឃាំងនៅព្រៃកូនង៉ែដដែល ។ ចំណែកឯអ្នកដែលគ្មានជាប់អ្វីទេ ត្រូវបញ្ជូនបន្តទៅកាន់ដំរំថ្មីទៀត ។ ការសួរចម្លើយបានចាប់ផ្តើមធ្វើឡើងចំពោះអ្នកទោសរួមជាមួយនឹងការធ្វើទារុណកម្មតាមវិធីដែលសាហាវបំផុតដូចជាចងព្យួរជើងទាញឡើងលើរួចទម្លាក់ចុះមកវិញ, បញ្ចូលម្ជុលក្នុងក្រចកម្តងបន្តិចៗ ។ល ។ ទិ ញ៉ិ ជាប្រធានភូមិកាត់ដៃ ឃុំឃ្សឹម បានរៀបរាប់ថាថ្វីត្បិតតែមានការធ្វើទារុណកម្មពិតមែន ប៉ុន្តែពុំមានសម្លាប់នៅនឹងកន្លែងទេ គឺត្រូវបញ្ជូនទៅសម្លាប់នៅចម្ការកៅស៊ូផ្អាក់ ឬចម្ការកៅស៊ូលេខ៦៤ (ក្រុមស្រាវជ្រាវ

*បានប្រើប្រាស់ម៉ាស៊ីនGPSរួចហើយកាលពីឆ្នាំ១៩៩៩) ។ ហេង បេ អាយុ៦៣ឆ្នាំ រស់នៅភូមិកាត់ដៃ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះបានដឹងពីការធ្វើទារុណកម្មលើអ្នកទោស ព្រមទាំងបានឃើញការបណ្តើរអ្នកទោសឲ្យធ្វើការបន្ទាប់ពីសួរចម្លើយនិងធ្វើទារុណកម្មរួចមក ។ ក្រៅពីអ្នកទោសជាប្រជាជន១៧មេសាទៅ នៅមានអ្នកទោសមួយប្រភេទទៀតដែលជាប្រជាជនមូលដ្ឋាន ។ ទោសកំហុសរបស់អ្នកទាំងនោះគឺបានប្រព្រឹត្តិខុសនឹងបទបញ្ជារបស់អង្គការដែលបានហាមប្រាម ដូចជាការលួច ឆក់ ខ្ជិលប្រអូស និងបញ្ហាផ្លូវភេទប្រហែលសនានា ។ អ្នកទោសប្រភេទនេះគឺត្រូវបានចាត់ទុកជាអ្នកទោសប្រភេទស្រាលដែលត្រូវទទួលការអប់រំណែនាំ ហើយក៏កម្រមាន ស្លាប់ដែរ ។ ជឹង ថ្វាង និង ជឹង កែវ (ជាប្រជាជនមូលដ្ឋាន) សព្វថ្ងៃរស់នៅភូមិត្រពាំងលាក់ និងភូមិវត្ត ស្នួល ឃុំស្នួល ស្រុកស្នួល គឺជាអ្នកទោសដែលបានរួចជីវិតពីការសម្លាប់ និងធ្វើទណ្ឌកម្មនៅព្រៃកូនដែំ ។*

*នួន សំអាត គឺជាប្រធានមន្ទីរសន្តិសុខនៅព្រៃកូនដែំ ។ សព្វថ្ងៃ សំអាត នៅមានជីវិតនៅឡើយ ហើយមានតួនាទីក្នុងរាជរដ្ឋាភិបាលកម្ពុជាទៀតផង ។ នួន សំអាត គឺជាមនុស្សតែម្នាក់គត់ដែលបានដឹងរឿងហេតុគ្រប់យ៉ាងនៅក្នុងមន្ទីរសន្តិសុខព្រៃកូនដែំ ។*

*មន្ទីរសន្តិសុខនេះ បានបញ្ចប់អណត្តិរបស់ខ្លួននៅពេលថ្ងៃរំដោះចូលមកដល់ ។ ស្លាកស្នាមជាច្រើន ដូចជាឈើឆ្កាង, ខ្នោះ និងឈាមក្រាលពាសពេញដី បានបន្សល់ទុកដើម្បីជាការបង្ហាញយ៉ាងច្បាស់ពីការធ្វើទារុណកម្មយ៉ាងសាហាវរបស់ខ្មែរក្រហមមកលើជនរងគ្រោះ និងកាន់តែធ្វើឲ្យសាច់ញាតិបងប្អូនរបស់ជនរងគ្រោះកាន់តែមានកំហឹងឆេះឆងកាន់តែខ្លាំងឡើងចំពោះអំពើរបៀបនេះ ។ រយៈពេលជាង២០ឆ្នាំបានកន្លងផុតទៅ គំនំទាំងឡាយហាក់ត្រូវបានរសាយពីជម្រៅចិត្តរបស់ប្រជាពលរដ្ឋទូទៅ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយក៏តុលាការមួយនឹងត្រូវបានធ្វើឡើងដើម្បីរកយុត្តិធម៌ដល់សង្គមជាតិ ក៏ដូចជាប្រជាពលរដ្ឋទូទាំងប្រទេសដែរ ។ ទោះជាមន្ទីរសន្តិសុខនៅព្រៃកូនដែំត្រូវរលប់បាត់ស្រមោលនាពេលបច្ចុប្បន្នក៏ដោយ ប៉ុន្តែការចងចាំរបស់ជនរងគ្រោះ និងប្រជាជនដទៃទៀតនៅតែចាំជានិច្ចនូវអំពើប្រល័យពូជសាសន៍ដែលបានកើតមានឡើង នៅតែមិនអាចបំភ្លេចបានឡើយ ។ ព្រៃក្រាស់ឃ្មឹកស្ទើរចូលទៅមិនបាននៃអតីតមន្ទីរសន្តិសុខព្រៃកូនដែំ ត្រូវបានស្គាល់យ៉ាងឥតស្រពិចស្រពិលថាជាមន្ទីររបស់សមមិត្តនួន សំអាត ដែលបានរៀបចំកន្លែងសួរចម្លើយយ៉ាងស្ងាត់ស្ងាត់បំផុត និងគ្មាននរណាដឹងកាលពីខ្លួននៅជាប្រធានសន្តិសុខនោះ ។ ប៉ុន្តែនៅពេលនេះ(ខែមិថុនា ឆ្នាំ២០០២) ខ្ញុំនិងក្រុមស្រាវជ្រាវបានលុកចូលទៅដល់ទីកន្លែងតាមការចង្អុលបង្ហាញពីប្រជាពលរដ្ឋដែលរស់នៅម្តុំនោះ(ភូមិកាត់ដៃ) ។*

## ស្រុកឆ្លូង

*១) ផ្ទះ ង សាមីន (មន្ទីរសន្តិសុខ)*

*លេខកូតភូមិសាស្រ្ត ១០០១០៣*

*រយៈកំពស់* **(N) 12º 15'05:34"**

*រយៈទទឹង* **(E) 105º 58'41:50"**

*នៅក្នុងទឹកដីឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ មានតែមន្ទីរសន្តិសុខមួយកន្លែងគត់ដែលមានឃុំឃាំងមនុស្សភាគច្រើនជាប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ និងប្រជាជនដែលត្រូវបានចោទថាជាបក្ខពួកខ្មែរស ។ មន្ទីរសន្តិសុខនេះបានបង្កើតឡើងនៅឆ្នាំ១៩៧០ គឺនៅក្នុងទឹកដីនៃតំបន់រំដោះរបស់ខ្មែរក្រហម ។ ង សាមីន គឺជាម្ចាស់ផ្ទះដែលខ្មែរក្រហមរឹបអូសយកធ្វើជាមន្ទីរសន្តិសុខ ។ តាំងពីឆ្នាំ១៩៧០ ង សាមីនព្រមទាំងគ្រួសារបានភៀសខ្លួនចេញទៅរស់នៅទីក្រុងភ្នំពេញ បន្ទាប់ពីផ្ទះរបស់គាត់ត្រូវបានស្នើសុំយកធ្វើជាមន្ទីរសន្តិសុខដែលមានឈ្មោះ កាន់ ណារ៉ាំ ជាប្រធាន ។ ការគ្រប់គ្រងមន្ទីរនេះបានបែងចែកជាពីរដំណាក់កាលគឺ ដំណាក់កាលទី១ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ។ ក្នុងដំណាក់កាលនេះ ការឃុំឃាំងបានកើតឡើងតែចំពោះប្រជាជនណាដែលត្រូវបានចោទថាជាបក្ខពួករបស់ខ្មែរស ដែលស្ទើរតែទាំងអស់គឺជាប្រជាជនមូលដ្ឋាន ។ អ្នកទោសមិនត្រូវបានដោះលែងមកវិញទេ ប៉ុន្តែបែជាត្រូវនាំយកទៅសម្លាប់នៅទីតាំងសម្លាប់មួយឈ្មោះថា ចម្ការម៉ៃសាក់ ។ ដំណាក់កាលទី២ គឺពីឆ្នាំ១៩៧៥ដល់ចុងឆ្នាំ១៩៧៨ ។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥គឺជាថ្ងៃដែលមន្ទីរសន្តិសុខនាផ្ទះង សាមីន បានផ្លាស់ប្តូរទៅជាមន្ទីរសន្តិសុខពេញលក្ខណៈនៃកម្ពុជាប្រជាធិបតេយ្យ ហើយស្របពេលដែល ង សាមីន និងក្រុមគ្រួសារបានធ្វើដំណើរវិលត្រឡប់មកកាន់ស្រុកកំណើតវិញតាម រយៈនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរ ។ ប៉ុន្តែក្នុងរយៈពេលដែលជម្លៀសនេះ ប្តីរបស់គាត់បានត្រូវសម្លាប់ចោលនៅតាមផ្លូវ ព្រោះតែជាអតីតមេព្រៃជិនាន់លន់ ណុល ។ ការផ្លាស់ប្តូរជាច្រើននៅក្នុងភូមិកំណើតរបស់គាត់បានធ្វើឲ្យមានការគិតមិនដល់ចំពោះរឿងហេតុទាំងឡាយដែលបានកើតឡើង ។ ផ្ទះដែលជាកម្មសិទ្ធស្របច្បាប់តាំងពីយូរយារណាស់មកហើយ នៅតែត្រូវបានដកហូតមកធ្វើជាសម្បត្តិរួមដដែល ។ ង សាមីននិងកូនៗបានធ្វើដំណើរហួសទៅរកទីជម្រកមួយថ្មីដែលរកឲ្យដោយខ្មែរក្រហម ។ ការនិយាយស្តីពីផ្ទះរបស់គាត់ត្រូវដកហូតធ្វើជាមន្ទីរសន្តិសុខប្រចាំឃុំឆ្លូងមិនត្រូវបានបង្ហើបឲ្យនរណាដឹងឡើយ ព្រោះតែចង់ថែរក្សាជីវិតទៅថ្ងៃមុខរបស់គាត់ (ង សាមីន) ។*

*នៅក្នុងដំណាក់កាលទី២នេះ ជនរងគ្រោះដែលត្រូវបានចោទថាជាបក្ខពួកខ្មែរសនោះ បានត្រូវបោសសំអាតអស់ហើយ ប៉ុន្តែជនរងគ្រោះក្រោយគឺជាប្រជាជន១៧មេសាដែលមានជាប់និន្នាការនយោបាយពីសង្គមចាស់តាមរយៈការធ្វើប្រវត្តិរូប ។ ប្រធានគ្រប់គ្រងមន្ទីរគឺជាមនុស្សថ្មីដែលមានឈ្មោះ ទ្រី ។ ចំណែក កាន់ ណារ៉ាំ (ប្រធានចាស់) បានត្រូវផ្លាស់ឲ្យទៅកាន់មុខតំណែងមួយថ្មីទៀតដែលគ្មាននរណាដឹង ។ មន្ទីរសន្តិសុខក្រោយបានត្រូវបង្កើតឲ្យមានកន្លែងសួរចម្លើយ កន្លែងកត់ឈ្មោះអ្នកទោស និងសរសេរចម្លើយសារភាព ។ ការធ្វើទារុណ*

កម្មបានកើតឡើងពេលដែលមានការសួរចម្លើយម្តងៗ ។ មានកម្មាភិបាលខ្មែរក្រហមប្រមាណ៥ទៅ៧នាក់នៅចាំត្រៀមខ្លួនបំពេញការងារតាមការបញ្ជារបស់ប្រធាន ។ ហាស់ ប៊ុនថេត អាយុ៥៤ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាឃុំឆ្លូង បានប្រាប់ថាបានឃើញមានការបណ្តើរមនុស្សទាំងខ្សែៗចេញពីមន្ទីរសន្តិសុខនេះយកទៅសម្លាប់នៅព្រៃចម្ការម៉ៃសាក់ដែលមានចម្ងាយប្រហែល១គីឡូម៉ែត្រប៉ែកខាងលិចមន្ទីរសន្តិសុខដោយកម្មាភិបាលដែលនៅប្រចាំការក្នុងមន្ទីរ ។ មានអ្នកទោសមួយចំនួនបានស្លាប់នៅក្នុងមន្ទីរសន្តិសុខ ដោយសារតែគ្មានថ្នាំសង្កូវគ្មានការថែរក្សា របបអាហារមិនគ្រប់គ្រាន់ និងអ្នកខ្លះទៀតបានស្លាប់ដោយសារតែការធ្វើទារុណកម្មពេលសួរចម្លើយ ។ ការស្លាប់នេះបានកើតឡើងជាហូរហែរ ។ ចំណែកឯការនាំយកមនុស្សទៅសម្លាប់ក៏កើតមានជាញឹកញាប់ដែរ ។ មានអ្នកទោសចេញ និងចូលទៅក្នុងមន្ទីរឃុំឃាំងនេះ ។ ហែម គឹមអេង អាយុ៣៤ឆ្នាំបានប្រាប់ ថាមានអ្នកទោសរាប់រយនាក់បានត្រូវបណ្តើរចេញពីមន្ទីរសន្តិសុខនៅផ្ទះឯ សាមីន យកទៅសម្លាប់ ។ ការគ្រប់ គ្រងមន្ទីរនេះបានបន្តមកដល់ចុងឆ្នាំ១៩៧៨ទើបត្រូវបានបញ្ចប់បន្ទាប់ពីថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ បានចូលមកដល់ ។ មន្ទីរនេះបានបញ្ចប់ទៅជាមួយនឹងជីវិតមនុស្សរាប់រយនាក់ដែលត្រូវបានសម្លាប់ ។ ស្លាកស្នាមជាច្រើនបានបន្សល់ទុកយ៉ាងគ្មានសណ្តាប់ធ្នាប់នៅពាសពេញមន្ទីរឃុំឃាំង ។

បន្ទាប់ពីថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ទៅ ឯ សាមីន បាននាំកូនៗរបស់គាត់មករស់នៅក្នុងផ្ទះរបស់គាត់វិញ ។ សំណល់ភស្តុតាងជាច្រើនបានត្រូវបោសសំអាត និងដុតបំផ្លាញចោល ។ ឈាមដែលប្រឡាក់នៅលើរនាបផ្ទះបានត្រូវដុះលាងសំអាត, តុសម្រាប់កត់យកចម្លើយ រួមនឹងបញ្ជីឯកសារ បញ្ជីឈ្មោះ កំណត់ហេតុសួរនៃសេចក្តីសារភាព និងឯកសារផ្សេងៗទៀត បានត្រូវដុតបំផ្លាញចោលទាំងអស់ ។ ឯ សាមីន បាននិយាយប្រាប់ពីរឿងនេះថា ធ្វើយ៉ាងនេះគឺដើម្បីបញ្ចប់នូវរឿងហេតុទាំងឡាយដែលបានកើតមានកន្លងមក ។ សាមីន បានបន្តទៀតថា ពេលដែលគាត់រើសយកឯកសារទាំងនោះទៅប្រមូលដុំមួយកន្លែងនោះ គាត់បានប្រទះឃើញបញ្ជីឈ្មោះមួយសន្លឹក ដែលក្នុងនោះមានឈ្មោះជាច្រើនដែលគាត់អះអាងថាធ្លាប់ស្គាល់នៅជិតខាងគ្នាកាលពីជំនាន់មុនរបបខ្មែរក្រហមចូលមកដល់ ។ សាមីន និយាយទៀតថា ប្រហែលជាពួកអ្នកទាំងនោះ(ឈ្មោះក្នុងបញ្ជី) ធ្លាប់ត្រូវបានចោទប្រកាន់ថាបានជាប់ខ្សែជាមួយនឹងបក្សពួកខ្មែរស ។ តាំងពីចូលមករស់នៅជាលើកទី២នាក្រោយថ្ងៃរំដោះរហូតមកដល់ពេលនេះ សាមីន តែងតែធ្វើពិធីបង្សុកូល អុជធូបទាននៅពេលបុណ្យទានម្តងៗដើម្បីប្រារព្ធដល់វិញ្ញាណក្ខន្ធឪពុករបស់គាត់ ព្រមទាំងជីវិតជាច្រើននាក់ទៀតដែលបានស្លាប់នៅលើផ្ទះរបស់គាត់កាលពីជំនាន់ខ្មែរក្រហម ។ ឯ សាមីន បានប្រាប់ពីអារម្មណ៍របស់គាត់ថា ជួនកាលហាក់ដូចជាបានឃើញ និងឮផ្ទាល់ត្រចៀកនូវសម្លេងស្រែកនៅលើផ្ទះរបស់គាត់ទាំងពេលថ្ងៃ និងយប់ ។ សាមីន បានសន្និដ្ឋានថាប្រហែលជាស្រែកនៅពេលសួរចម្លើយហើយ ព្រោះស្តាប់ទៅហាក់ដូចជាត្រូវទទួលទណ្ឌកម្មខ្លាំងណាស់ ។ ប៉ុន្តែមកដល់សព្វថ្ងៃនេះ គ្មានអ្វីដែលមករំខានដល់អារម្មណ៍របស់ សាមីន ទៀតឡើយ ព្រោះគាត់យល់ឃើញ

តាមផ្លូវធម៌ថា ពិតជាបានទៅចាប់ជាតិថ្មីអស់ទៅហើយ ។ ផ្ទះរបស់ សាមីនសព្វថ្ងៃគឺនៅតែថែរក្សាទ្រង់ទ្រាយដើមដដែលគ្មានដួលដុសអ្វីបន្តិចឡើយ សូម្បីតែជញ្ជាំងផ្ទះជាន់ក្រោមដែលធ្វើពីឥដ្ឋនិងស៊ីម៉ង់ក៏នៅដដែលដែរ ។ កូនស្រីតូចៗកាលពីជំនាន់ខ្មែរក្រហមរបស់ សាមីន បច្ចុប្បន្នគឺជាគ្រូពេទ្យប្រចាំឃុំឆ្លង ។ គ្លីនិកតូចមួយបានបើកឡើងនៅក្នុងផ្ទះជាន់ក្រោមរបស់ សាមីន ។ ពេលដែលខ្ញុំនិងក្រុមស្រាវជ្រាវចូលទៅសាកសួរព័ត៌មាន មានអ្នកជម្ងឺពីរបីនាក់កំពុងសម្រាកព្យាបាលនៅក្នុងផ្ទះរបស់គាត់ ។ ម្ចាស់ដែលគ្រប់គ្រងផ្ទះនេះ គឺមានតួនាទីជាអ្នកជួយសង្គ្រោះជីវិតមនុស្សទូទៅ មិនដូចអ្នកដែលគ្រប់គ្រងផ្ទះនេះកាលពីជំនាន់ខ្មែរក្រហមទេដែលគិតតែរកឡេសសម្លាប់មនុស្សគ្មានឈប់ឈរ ។

៧) ចម្ការម៉ៃសាក់ (ទីតាំងពិឃាត)

លេខកូតភូមិសាស្ត្រ ១០០១០៤

រយៈកំពស់ **(N) 12º 14'56:59"**

រយៈទទឹង **(E) 105º 58'09:88"**

ជនរងគ្រោះដែលបានសួរចម្លើយរួចរាល់ហើយត្រូវចាត់ចូលក្នុងបញ្ជីដែលត្រូវសម្លាប់ គឺពិតជាបានបញ្ជូនមកកាន់ចម្ការម៉ៃសាក់ដើម្បីសម្លាប់ ។ ចម្ការម៉ៃសាក់ ស្ថិតនៅក្នុងភូមិជ្រោយថ្មក្រោម ឃុំឆ្លង ស្រុកឆ្លង ខេត្តក្រចេះ ។ ការសម្លាប់មនុស្សបានប្រព្រឹត្តិទៅនៅខាងជើងវត្តភ្នំព្រះតែប្រមាណ៥០ម៉ែត្រប៉ុណ្ណោះ ។ តាំងពីឆ្នាំ១៩៧០ រហូតមកទល់នឹងចុងឆ្នាំ១៩៧៨ ការសម្លាប់មនុស្សនៅចម្ការម៉ៃសាក់គឺមានជាហូរហែរ ។ ជនរងគ្រោះរាប់រយនាក់ដែលបានបញ្ជូនមកពីមន្ទីរឃុំឃាំងនាផ្ទះ ៦ សាមីន និងកន្លែងផ្សេងទៀតបានត្រូវសម្លាប់ដោយគ្មាននរណាម្នាក់មានជីវិតរស់ឡើយ ។ ក្រោយពីការសម្លាប់ សាកសពទាំងអស់បានទម្លាក់ចូលទៅក្នុងរណ្តៅរាប់រយដែលបានជីករួច ។ ក្នុងសម្ដីរបស់ ហាស់ ប៊ុនថេតដែលបានសម្ភាសន៍ បាននិយាយប្រាប់ថាមានសាកសពចាប់ពីពីរនាក់ឡើងទៅដែលត្រូវបានរុញចូលតែមួយរណ្តៅ ។ ប៊ុនថេត បានសន្និដ្ឋានថាមានរណ្តៅរាប់រយនៅក្នុងបរិវេណចម្ការម៉ៃសាក់ ។ ឯចំនួនជនរងគ្រោះវិញគឺមានចំនួនចាប់ពី២០០នាក់ឡើងទៅ ។ ហែម គឹមអេង បានរៀបរាប់ថាបានឃើញមានស្លាកស្នាមរណ្តៅនៅពាសពេញព្រៃនៅចម្ការម៉ៃសាក់ ព្រមទាំងបានឃើញមានឆ្អឹងលលាដ៍ក្បាល និងឆ្អឹងផ្សេងៗទៀតជាច្រើននៅក្រោយថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ក្រៅពីជនរងគ្រោះដែលបានបញ្ជូនមកពីផ្ទះ ៦ សាមីន នៅមានជនរងគ្រោះដទៃទៀតដែលបានបញ្ជូនមកសម្លាប់តែម្តងដោយពុំមានការឃុំឃាំងឡើយ ។ ព្រឹត្តិការណ៍នេះបានកើតឡើងនៅមុនពេលដែលកើតមានមន្ទីរសន្តិសុខនៅផ្ទះ ៦ សាមីនទៅទៀត ។ ហ៊ុន វុនបានអះអាងប្រាប់ដូច្នេះថាគាត់ជាអ្នកដែលបានដឹងយ៉ាងប្រាកដពីការនាំជនរងគ្រោះមកសម្លាប់ដោយមិនមានការឃុំខ្លួនជាមុនសិន ។ រហូតមកដល់បច្ចុប្បន្ននេះ ទីតាំងសម្លាប់មួយផ្នែកបានក្លាយទៅជាបរិវេណនៃមូលដ្ឋានកងទ័ពប្រចាំស្រុកឆ្លង ។